ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


និយ័តករទូរគមនាគមន៍កម្ពុជា


លេខ :....២៤៣៦....ន.ទ.ក.

# សេចក្តីណែនាំ

## ស្តីពី

## ការគ្រប់គ្រង ការប្រើប្រាស់ និងការថែទាំយានយន្ត

ដើម្បីគ្រប់គ្រង ប្រើប្រាស់ និងថែទាំយានយន្តដែលជាទ្រព្យសម្បត្តិរដ្ឋឱ្យបានគត់មត់ ត្រឹមត្រូវ ស្របតាមស្តង់ដារបច្ចេកទេស ខ្ញុំសូមធ្វើការណែនាំដល់ឯកឧត្តម លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ ដូចខាងក្រោម÷

១. ត្រូវលាងសម្អាតយានយន្តឱ្យបានស្អាតល្អជាប្រចាំ (ទាំងក្នុង និងក្រៅ) បន្ទាប់ពីបំពេញបេសកកម្ម ឬប្រើប្រាស់រួច

២. ត្រូវផ្លាស់ប្តូរប្រេងម៉ាស៊ីន និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរបស់យានយន្តឱ្យបានទៀងទាត់ស្របតាមស្តង់ដារបច្ចេកទេស

៣. ក្នុងករណីយានយន្តមានបញ្ហាម៉ាស៊ីន គ្រឿងក្រោម ប្រព័ន្ធភ្លើង និងទឹកថ្នាំ ត្រូវធ្វើការជួសជុលភ្លាមឱ្យស្របតាមស្តង់ដាបច្ចេកទេស។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តម លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ក្រោមឱវាទ ន.ទ.ក ត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃ អង្គារ ៦ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២០

ប្រធាន

ចោង ចិន្តា

**ចម្លងជូន÷**

- ឯកឧត្តមសមាជិក
- គ្រប់នាយកដ្ឋាន និងអង្គភាព
  “ដើម្បីផ្សព្វផ្សាយអនុវត្ត”
- ឯកសារ-កាលប្បវត្តិ